គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងវិស័យការងារ និងអង្គការសង្គមស៊ីវិល

ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣
មជ្ឈមណ្ឌលដាយកូនៀ, រាជធានីភ្នំពេញ

# សារៈនៃច្បាប់ស្តីពីការងារ

- ច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។

- យោងតាមមាត្រា១ នៃ ចកង៖ ច្បាប់ការងារដាក់ចេញវិធានការនានាដែលគ្រប់គ្រងទំនាក់ទំនងការងាររវាង និយោជកដែលមិនមែនជារដ្ឋ និងកម្មករនិយោជិត។ ទំនាក់ទំនងនេះ ត្រូវបានបង្កើតឡើងដោយកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតម្នាក់ៗ។

- ច្បាប់នេះ អនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា កសិកម្ម ដឹកជញ្ជូនតាមផ្លូវគោក តាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន...***<u>ព្រមទាំងវិជ្ជាជីវៈនៃសេរីភាពសមាគម ឬក្រុមប្រភេទណាមួយ</u>***(ឧ. សមាគម, អង្គការមិនមែនរដ្ឋាភិបាល, សមាគមធនាគារ...)

# កត្តាចំបងៗដែលនាំឱ្យមានការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យការងារចំពោះ NGOs

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលប្រើកម្មករនិយោជិត គឺត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីការងារ។
- ការពង្រឹងយន្តការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់ស្ថាប័នរាជរដ្ឋាភិបាលរួមទាំងក្រសួងការងារ។
- និន្នាការនៃការពង្រឹងការគ្រប់គ្រងបុគ្គលិកបរទេសដែលធ្វើការនៅប្រទេសកម្ពុជា ពិសេសអង្គការសង្គមស៊ីវិល។

# ច្បាប់ស្តីពីការងារ និងអនុលោមភាព

ក/ ប្រកាសជូនដំណឹងបើកសហគ្រាស និងបិទសហគ្រាស

ខ/ បទបញ្ជាផ្ទៃក្នុងក្នុងសហគ្រាស ឬគ្រឹះស្ថាន

គ/ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង បសស

ឃ/ ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស

ង/ ការបង្កើតឱ្យមានប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន

# ក/ ប្រកាសជូនដំណឹងបើកសហគ្រាស និងបិទសហគ្រាស

## យោងតាមច្បាប់ស្តីពីការងារមាត្រា ១៧៖

- និយោជកទាំងអស់ដែលត្រូវអនុវត្តច្បាប់ស្តីពីការងារនេះ ត្រូវធ្វើ**សេចក្តីប្រកាសជូនដំណឹង**ទៅក្រសួងទទួលបន្ទុកវិស័យការងារ នៅពេលបើកសហគ្រាស គ្រឹះស្ថាន។
- សេចក្តីប្រកាសជូនដំណឹងនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងដាក់ជូនក្រសួងទទួលបន្ទុកវិស័យការងារ (បច្ចុប្បន្នភាព ធ្វើតាមអនឡាញ)។
- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសមានគោលបំណងផ្តល់ព័ត៌មានអំពីទីតាំងនៃសហគ្រាស និងព័ត៌មានអំពីកម្មករនិយោជិត។

## យោងតាមច្បាប់ស្តីពីការងារមាត្រា ៣៦៩៖

- និយោជកណា ដែលបានចាប់ផ្តើមដំណើរសហគ្រាស ឬគ្រឹះស្ថាន ដោយមិនបានធ្វើសេចក្តីប្រកាសនេះ ប្រឈមនឹងការពិន័យជាប្រាក់ចាប់ពី ៦១ ទៅ ៩០ ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។

# ខ/ បទបញ្ជាផ្ទៃក្នុងក្នុងសហគ្រាស ឬគ្រឹះស្ថាន

*យោងតាមច្បាប់ស្តីពីការងារមាត្រា២២ និង២៣៖*

- សហគ្រាស ឬគ្រឹះស្ថានដែលមាន**កម្មករនិយោជិតចាប់ពី ៨ នាក់ឡើងទៅ**ត្រូវមានឯកសារមួយឈ្មោះថា **បទបញ្ជាផ្ទៃក្នុង**។
- បទបញ្ជាផ្ទៃក្នុងនេះ ត្រូវចុះ**ទិដ្ឋការយល់ព្រមដោយអធិការការងារ**មុននឹងយកទៅអនុវត្តបាន។
- សហគ្រាស ឬគ្រឹះស្ថានដែលពុំមានបទបញ្ជាផ្ទៃក្នុងប្រឈមនឹងការ**ពិន័យប្រាក់ពី ១០ ថ្ងៃ ដល់ ៣០ថ្ងៃ** នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។

# ខ/ បទបញ្ជាផ្ទៃក្នុងក្នុងសហគ្រាស ឬគ្រឹះស្ថាន

- បទបញ្ជាផ្ទៃក្នុងត្រូវយកតាមលំនាំបទប្បញ្ញត្តិច្បាប់ស្តីពីការងារ និងមានចែងពាក់ព័ន្ធនឹង៖
  - លក្ខខណ្ឌនៃការជ្រើសរើសបុគ្គលិក
  - របៀបគណនា និងបើកប្រាក់ឈ្នួលនិងអត្ថប្រយោជន៍
  - តាវកាលិកជាសម្ភារៈ
  - ម៉ោងធ្វើការ
  - ការឈប់សម្រាក និងការសុំច្បាប់ឈប់
  - ការជូនដំណឹង
  - វិធានការអនាម័យ និងសន្តិសុខ
  - កាតព្វកិច្ចកម្មករនិយោជិត
  - ការដាក់វិន័យ

# គ/ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង បសស

- នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្ពុជាបានប្រកាសឱ្យប្រើច្បាប់ថ្មីមួយស្តីពី របបសន្តិសុខសង្គម ដែលមានវិសាលភាពលើជនទាំងឡាយណាធ្វើការក្នុងវិស័យឯកជនក្រោមច្បាប់ស្តីពីការងារ។ ច្បាប់ថ្មីនេះ ចែងពីក្របខ័ណ្ឌគតិយុត្តសម្រាប់ផ្នែកទាំងអស់រួមមាន៖
    - ➢ ផ្នែកប្រាក់សោធន
    - ➢ ផ្នែកថែទាំសុខភាព
    - ➢ ផ្នែកហានិភ័យការងារ និង
    - ➢ ផ្នែកនិកម្មភាពការងារ

# ឃ/ ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស

## យោងតាមច្បាប់ស្តីពីការងារមាត្រា ២៦១, ២៦៣ និង២៦៤

- សហគ្រាស ឬគ្រឹះស្ថានអាចជ្រើសរើសបុគ្គលិកបរទេសឱ្យធ្វើការបានសម្រាប់មុខតំណែងអ្នកបច្ចេកទេស ឬវិជ្ជាជីវៈ។
- សហគ្រាស ឬគ្រឹះស្ថាន**ត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងការងារ** មុននឹងជ្រើសរើសបុគ្គលិកមកធ្វើការ។

  - ➢ ស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស។
  - ➢ យកកិច្ចសន្យាការងារជាមួយបុគ្គលិកបរទេសទៅចុះបញ្ជីនៅនាយកដ្ឋានការងារ/មន្ទីរការងារ។
  - ➢ នាយកគ្រឹះស្ថានត្រូវរៀបចំឱ្យបុគ្គលិកបរទេសនោះស្នើសុំប័ណ្ណការងារ និងសៀវភៅការងារពីក្រសួងការងារ។

# ឃ/ ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស (ត)

**យោងតាមច្បាប់ស្តីពីការងារមាត្រា ៣៦៩**

- នាយកសហគ្រាស ឬគ្រឹះស្ថានដែលបានប្រើប្រាស់ហត្ថពលកម្មបរទេសដោយគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសល្មើសនឹងមាត្រា ២៦៤ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៦០ថ្ងៃ ទៅ ៩០ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ថ្ងៃ ទៅ១ខែ។

# ឃ/ ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស (ត)

**សេចក្តីជូនដំណឹងស្តីពី ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤**

**ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** : ០២៦៧/២៣ ក.ប/ស.ជ.ណ.ន.ហ

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិមាត្រា១ នៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានតម្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤ ត្រូវដាក់សំណើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤ **ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣** តាមរយៈគេហទំព័រ **www.fwcms.mlvt.gov.kh**។

ក្នុងករណី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន បានប្រើប្រាស់ហត្ថពលកម្មបរទេសដោយគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស ល្មើសនឹងមាត្រា២៦៤ យោងមាត្រា៣៦៩ នៃច្បាប់ស្តីពីការងារ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីហុកសិបមួយថ្ងៃទៅកៅសិបថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីប្រាំមួយថ្ងៃទៅមួយខែ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣
**រដ្ឋមន្ត្រី**

**ហេង ស្ួរ**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥*

# ង/ ការបង្កើតឱ្យមានប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស

## យោងតាមច្បាប់ស្តីពីការងារមាត្រា ២៨៣៖

- នៅគ្រប់សហគ្រាស ឬគ្រឹះស្ថានដែលជាធម្មតាមានកម្មករនិយោជិតយ៉ាងតិច ៨នាក់ កម្មករនិយោជិតត្រូវបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ដើម្បីជាតំណាងតែមួយគត់របស់កម្មករនិយោជិតទាំងអស់នៅក្នុងសហគ្រាស...។

## ប្រកាសលេខ ៣០២ ស្តីពី ប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន

- ប្រកា១ កថាខណ្ឌ ២&៣៖ ប្រភេទសហគ្រាស គ្រឹស្ថានដែលត្រូវឱ្យមានប្រតិភូបុគ្គលិកជាដាច់ខាត មានជាអាទិ៍៖ សហគ្រាសគ្រឹះស្ថានឧស្សាហកម្ម ពាណិជ្ជកម្ម រ៉ែ សំណង់ សេវា ធនាគារ កសិកម្ម កំពង់ផែ សណ្ឋាគារ ភោជនីយដ្ឋាន សាលាបង្រៀន និងផលិតកម្មផ្សេងៗ។
- ប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រតិភូបុគ្គលិកជំនួយ ត្រូវបានបោះឆ្នោតជ្រើសរើសដោយកម្មករនិយោជិតសម្រាប់អាណត្តិ ២ឆ្នាំ។

# សូមអរគុណ

# Thank you!